សម្លេងខ្មែរនៅបរទេស

# សេចក្ដីប្រកាសសាធារណរដ្ឋខ្មែរ ដោយលោកអ៊ិន-តាំ ប្រធានរដ្ឋសភា

ដកស្រង់ចេញពី «អ្នកជាតិនិយម»
ឆ្នាំទី១២ លេខ៥៣០ សប្ដាហ៍១២-១៨ តុលា ១៩៧០ ទំព័រ៦-៧



លោកអ៊ិន-តាំ
ប្រធានសភាជាតិ

ប្រជារាស្ត្រខ្មែរ ជាជនជាតិមួយស្នេហាសន្តិភាពយ៉ាងខ្ជាប់ខ្ជួនតាំងតែពីបុរាណកាលមក ដោយបានបង្កើតជាសង្គមមនុស្សមួយនៅលើដែនដីសុវណ្ណភូមិ ហើយបានរស់នៅក្រោមការត្រួតត្រានៃជនមួយក្រុម ដែលមានវណ្ណៈជាស្ដេចកាន់អំណាចផ្ដាច់ខ្លួន ជាសម្បូរណាញ្ញាសិទ្ធិរាជ ។ អំណាចនេះត្រូវបន្តពូជផារពីមួយទៅមួយ តាំងពីច្រើនសតវត្សមកដល់សម័យសីហនុ ។ ក្រុមនេះគេដណ្ដើមគ្នាឡើងសោយរាជ្យ រហូតដល់ហ៊ានយកទឹកដីដូររាជ្យនោះក៏មាន ។ ដើម្បីឲ្យគេនៅក្នុងវង្សបានយូរ គេត្រូវបំបែករាស្ត្រ បំបែកមន្ត្រីឲ្យម្នាក់និយាយដើមម្នាក់អាក្រក់ ។ ពួកគេណាមួយដែលមិនបានសោយរាជ្យ គេត្រូវបានទទួលបុព្វសិទ្ធិពិសេស ចាប់តាំងពីកំណើតមក ។ គេបង្កើតពាក្យសំរាប់និយាយរវាងគ្នាគេក្ដី ជារាជស័ព្ទផ្សេងដោយឡែកពីភាសារាស្ត្រ ក្នុងគោលគំនិតតាំងខ្លួនជាអាទិទេពជាទីសក្ការៈរបស់រាស្ត្រ ។

តាំងពីជំនាន់ដើម រាស្ត្រខ្មែរដោយបន្សាបនូវពិសសាហាវនៃអំណាចផ្តាច់ការរបស់ស្តេច ដោយមធ្យោបាយបង្កើតជាប្រពៃណីមួយ ឲ្យស្តេចគោរពនូវច្បាប់ដែលហៅថា «ទសពិធរាជធម៌» ដែលមានលក្ខណៈជាធម្មនុញ្ញតូចមួយមាន១០មាត្រាប៉ុណ្ណោះ ហើយដោយផ្អែកទៅលើគោលមនុស្សធម៌ យុត្តិធម៌ តាមឧត្តមគតិនៃព្រះពុទ្ធសាសនា ។ ឯទសពិធរាជធម៌ទាំង១០គឺ ៖

១- ទាន: ការឲ្យអំណាច ដើម្បីដោះស្រាយបញ្ហាជីវភាពទន់ខ្សោយរបស់រាស្ត្រ

២- សីល: កាន់អំពើយុត្តិធម៌ចំពោះសង្គមជាតិ ដោយបើកឲ្យមានសមភាព-សេរីភាព-ភាតរភាព=វឌ្ឍនភាព និងសុភមង្គលដល់រាស្ត្រ ។

៣- បរិច្ចាគ: បដិសេធចោលនូវអស្មិមានះ អាត្មានិយមឲ្យអស់ចេញពីសន្តានចិត្តរបស់ខ្លួន ។

៤- អាជីវ: ប្រកាន់សច្ចៈទៀងត្រង់ ។

៥- មទ្ទវ: មានឥរិយាបថស្លូតបូតសុភាពរាបសារដោយកាយវាចា ។

៦- តប: រក្សាសីលប្រាំចាំសីលប្រាំបី ។

៧- អកោធ: មិនធ្វើឲ្យអ្នកផងក្តៅក្រហាយដោយសារខ្លួន ។

៨- អវិហឹសា មិនបៀតបៀនព្យាបាទអ្នកដទៃឲ្យវិនាស ដោយសារកំហឹងរបស់ខ្លួន ។

៩- ខន្តី មានចិត្តអំណត់អត់ធន់ ។

១០- អវិរោធ: មិនជិះជាន់ច្បាប់ គឺមិនយកច្បាប់មកទ្រាប់អង្គុយ ។

ក៏ប៉ុន្តែ ប្រវត្តិសាស្ត្ររបស់ប្រទេសខ្មែរបានឲ្យយើងដឹងថា ទោះបីមានច្បាប់ទសពិធទាំង១០យ៉ាងខាងលើនោះ តម្រូវឲ្យស្តេចគោរពតាមក៏ពិតមែន តែច្បាប់នេះអាស្រ័យទៅលើចិត្តស្តេចតែខ្លួនឯង បើស្តេចនោះមានអាងធម៌២យ៉ាងគឺ ៖

- ហិរិ: សេចក្តីខ្មាស់អៀនក្នុងការប្រព្រឹត្តអំពើអាក្រក់១

- ឱត្តប្ប: សេចក្តីខ្លាចតក់ស្លុតចំពោះអំពើអាក្រក់១

ទើបអាចប្រព្រឹត្តទៅតាមទសពិធរាជធម៌នោះបាន ប៉ុន្តែតាមការពិត គេឃើញស្តេចមិនប្រព្រឹត្តតាមទសពិតរាជធម៌ទេ ដោយមកពីគ្មានហិរិ: និងឱត្តប្បៈនៅក្នុងខ្លួននោះឯង ។

ដោយស្តេចនីមួយៗតគ្នាមិនបានកាន់ទសពិធរាជធម៌នេះហើយ បានជាបណ្តារាស្ត្រមានសេចក្តីក្តៅក្រហាយរងទុក្ខដោយសារស្តេចជិះជាន់ ហើយរកមធ្យោបាយជាអាវុធ កំចាត់អំពើជិះជាន់របស់ស្តេចមិនបាន ក៏នាំគ្នាបង្កើតពាក្យប្រទេចផ្តាសាបញ្ឆិតបញ្ឆៀងតៅលើជនណាមួយ ផ្តេសផ្តាសពេកថា «អាចំកួតហ្លួង» ។ ប្រវត្តិសាស្ត្រខ្មែរបានបង្ហាញឲ្យឃើញទៀតថា មានរាស្ត្របានសាកល្បងងើបប្រឆាំងនឹងអំណាចផ្តាច់ការរបស់ស្តេចជាហូរហែ ប៉ុន្តែគ្រប់តែពេលត្រូវគេបង្ក្រាបយ៉ាងសាហាវ

ការវិវត្តន៍របស់មនុស្សលោក ចេះតែមានដំណើរទៅមុខឥតថយក្រោយ ប្រជា

រាស្ត្រខ្មែរក៏ដូចជាប្រជារាស្ត្រទូទៅនៅក្នុងសកលលោកដែរ ត្រូវការ ៖
- សេរីភាព
- សមភាព
- ភាតរភាព
- វឌ្ឍនភាព
- សុភមង្គល

ក្នុងដំណើររំដោះជាតិពីកណ្តាប់ដៃនៃពួកស្តេច ឆ្ពោះទៅរកគោលដៅទាំង៥ដូចខាងលើនេះ ប្រជារាស្ត្រខ្មែរតែងតែប្រើមធ្យោបាយសន្តិវិធី ប្រើច្បាប់ដើម្បីរក្សាលក្ខណ:ខ្លួនជាជាតិស្នេហាសន្តិភាព ។

ក្រោយពីសង្គ្រាមលោកលើកទី២បានបញ្ចប់ទៅ ប្រជាជាតិក្នុងសកលលោកបានរួមគ្នាធ្វើសេចក្តីថ្លែងជាសកលនូវសិទ្ធិនៃមនុស្សប្រការ២១ វគ្គទី៣នៃសេចក្តីថ្លែងជាសកលនូវសិទ្ធិមនុស្សបានចែងថា ត្រូវទុកឆន្ទ:របស់ប្រជារាស្ត្រជាគ្រឹះអំណាចនៃអនុភាពសាធារណ: ។ ឆន្ទ:នេះត្រូវសំដែងដោយវិធីបោះឆ្នោតសុចរិត ដែលត្រូវធ្វើតាមកំណត់កាលដោយវិធីបោះឆ្នោតសកល និងដោយសមភាព ហើយនិងដោយសម្ងាត់ ឬក៏ដោយនីតិក្រមដែលមានន័យដូចគ្នាខាងលើនេះ ក្នុងការធានារ៉ាប់រងដល់សេរីភាពនៃការបោះឆ្នោតនោះ ។

ដោយអនុលោមទៅតាមគោលការណ៍ខាងលើនេះ ខ្មែរស្នេហាជាតិមួយក្រុមមានសេចក្តីក្លាហាន បានក្រោកឡើងចាប់ផ្តើមរៀបចំធ្វើរដ្ឋធម្មនុញ្ញមួយ ដើម្បីកំរិតព្រំដែនអំណាចរបស់ស្តេចនិងអំណាចរបស់រាស្ត្រ ។

រដ្ឋធម្មនុញ្ញនេះបានប្រកាសឲ្យប្រើពីឆ្នាំ១៩៤៧រហូតមក ដោយមានការរអាក់រអួលជានិច្ចកាល ។ ការរអាក់រអួលនេះបណ្តាលមកពីស្តេចសីហនុ ជាស្តេចចុងក្រោយបង្អស់ ក្នុងចំណោមស្តេចគ្រប់គ្រងប្រទេសខ្មែរ ដែលគ្មានទសពិធរាជធម៌នោះ។ ស្តេចសីហនុមានពុតត្បុតអាក្រក់ចម្លែក ដោយចេះធ្វើមាយាប្រជាភិថុតិចំពោះរាស្ត្រតែសំបកក្រៅ ដោយប្រើល្បិចកិច្ចកលក្តោបអំណាច ឲ្យដៃឆ្វេងកេងកាវទាញយកវិញ ដោយដៃស្តាំសន្ធប់រដ្ឋធម្មនុញ្ញ នៅពីក្រោមអំណាចខ្លួន ដូច្នោះហើយបានជារដ្ឋធម្មនុញ្ញត្រូវកែប្រែវិលចុះវិលឡើងច្រើនលើកច្រើនសា ។ នរណាហ៊ានការពាររដ្ឋធម្មនុញ្ញនេះ នរនោះត្រូវស្លាប់ខ្លួនដូចលោកប្រធាន អៀវ-កើស ជាឧទាហរណ៍ស្រាប់ ។ រដ្ឋសភាជាអង្គការតំណាងលទ្ធិប្រជាធិបតេយ្យ ដែលមានករណីយកិច្ចការពាររដ្ឋធម្មនុញ្ញ ក៏ត្រូវទទួលរងគ្រោះ និងអំពើជិះជាន់របស់ស្តេចចុងក្រោយនេះដែរ ។

តាំងពីចាប់អនុវត្តរដ្ឋធម្មនុញ្ញចំនួន២៣ឆ្នាំនេះ មានរដ្ឋសភា៦នីតិកាលបានបន្តៗគ្នា ។ ក្នុង៦នីតិកាលនេះ នីតិកាលទី១-២-៣ ត្រូវរលាយក្នុងអាណត្តិគឺ ៖

រដ្ឋសភាទី១ បានបើកសម័យពីថ្ងៃទី២១ មករា ១៩៤៨ ត្រូវរលាយទៅវិញពីថ្ងៃទី១៧ កញ្ញា ១៩៤៩ ហើយបន្ទាប់មកអតីតប្រធាន អៀវ-កើស ត្រូវគេលបសម្លាប់

ចោល ។

រដ្ឋសភាទី២ បើកសម័យប្រជុំថ្ងៃទី៤ តុលា ១៩៥១ រលាយទៅវិញនៅថ្ងៃទី១៣ មករា ឆ្នាំ១៩៥៣ ។

រដ្ឋសភាទី៣ បើកសម័យប្រជុំថ្ងៃទី១ តុលា ១៩៥៥ រលាយទៅវិញនៅថ្ងៃទី៨ មករា ១៩៥៨ ។

រួចខ្លួនតែរដ្ឋសភាទី៤និងទី៥ដែលមានអាយុកាលគ្រប់ឆ្នាំមិនបានរលាយ ព្រោះសមាជិកនៃរដ្ឋសភាទាំងពីរនីតិកាលនេះ បានកើតឡើងដោយស្តេចសីហនុ បានចាត់ឈ្មោះឲ្យទៅឈរក្នុងមណ្ឌលនីមួយៗ គ្មានគូប្រជែង ។ រីឯរដ្ឋសភានៃនីតិកាលទី៦នាបច្ចុប្បន្ននេះ មានអ្នកតំណាងរាស្ត្រ៨២រូប ដែលបានជាប់ឆ្នោតដោយសុចរិតអំពីឆន្ទៈដ៏បរិសុទ្ធនៃរាស្ត្រ ក្នុងចំនួនបេក្ខជន៤១៥នាក់ កាលពីថ្ងៃទី១១ កញ្ញា ១៩៦៦។

សភានីតិកាលទី៦នេះ បានខិតខំធ្វើការបំរើរាស្ត្រពេញសមត្ថភាព ដោយពុះពារឧបសគ្គគ្រប់យ៉ាង ក្នុងកិច្ចការពារផលប្រយោជន៍សិទ្ធិសេរីភាពរបស់រាស្ត្រ ដែលនាំឲ្យសីហនុគំរាមកំហែងសង្កត់សង្កិនគ្រប់បែបយ៉ាង មានតំណាងរាស្ត្រ៣នាក់ត្រូវបាត់ខ្លួន ដោយឧបាយកលសម្ងាត់របស់សីហនុ តំណាងរាស្ត្រខ្លះត្រូវជាប់គុកក៏មាន

អ្នកតំណាងរាស្ត្រទាំងអស់ ត្រូវហាមឃាត់មិនឲ្យចូលរួមក្នុងបុណ្យឯករាជ្យនិងក្នុងសមាជាតិ ។ ធ្ងន់ទៅទៀត ស្តេចសីហនុដែលជាស្តេចចុងក្រោយ បានប្រើអំណាចផ្តាច់ការលក់ដីឲ្យពួកយៀកកុង-យួនខាងជើង តាំងមូលដ្ឋានសឹកខុសពីនយោបាយអព្យាក្រឹត្យចុងក្រោយរបស់សាមីខ្លួន គឺពេលប្រជារាស្ត្រសំដែងសេចក្តីក្តៅក្រហាយ ចំពោះការជិះជាន់នៃទ័ពបរទេស ស្តេចសីហនុបានទុករាស្ត្ររបស់ខ្លួនតាំងប្រទេសថាជាក្បត់ ហើយខ្លួនទៅរួមគំនិតជាមួយខ្មាំងវាយជាតិរបស់ខ្លួន ។ កំហុសចុងក្រោយរបស់ស្តេចសីហនុនេះ បានធ្វើឲ្យសភាតាំងពីរទម្លាក់សាមីខ្លួននៅវេទិកានេះចេញពីតំណែងប្រមុខរដ្ឋ ចាប់តាំងពីថ្ងៃទី១៨ មីនា ១៩៧០ ។

ប្រវត្តិសាស្ត្រខ្មែរមុនចម្បាំងលើកទី២ ដែលខ្មែររស់នៅអាស្រ័យទសពិធរាជធម៌ក្តី ក្រោយចម្បាំងលើកទី២ ដែលខ្មែររស់នៅអាស្រ័យរដ្ឋធម្មនុញ្ញជាគោលចរិកក្តី បានបង្ហាញឲ្យឃើញថា ស្តេចពុំព្រមបោះបង់អំណាចផ្តាច់ការផ្ទាល់ខ្លួនទាល់តែសោះ ហើយបំបាត់ជីវិតពលរដ្ឋចោលខ្លះឬសុខចិត្តឲ្យបាត់បង់ទឹកដីខ្លះចុះ ឲ្យតែខ្លួនបានរក្សាអំណាចផ្ទាល់របស់ខ្លួន ។

ដោយយោលទៅលើគុណវិបត្តិជាច្រើននៃលទ្ធិរាជានិយម ដូចបានរៀបរាប់មកខាងលើ

- ដោយស្របនឹងគោលរដ្ឋធម្មនុញ្ញសហប្រជាជាតិ ដែលស្តីពីសិទ្ធិនៃប្រជាជាតិនីមួយៗ ក្នុងការចាត់ចែងខ្លួនទៅដោយសេរី ។
- ដោយគោរពឆន្ទៈរបស់ប្រជារាស្ត្រ ដែលបានសំដែងក្នុងព្យុហយាត្រាកាលពីថ្ងៃទី១១ មេសា ១៩៧០ និងតាមញត្តិដែលមានជាបន្តបន្ទាប់គ្នាមកទៀត ។

- ដោយគោរពតាមក្រមលេខ៨៨២-៧០ ចុះថ្ងៃទី៨ តុលា ១៩៧០ ដើម្បី
- សេរីភាព
- សមភាព
- ភាតរភាព
- វឌ្ឍនភាព
- និងសុភមង្គល

នៃប្រជារាស្ត្រខ្មែរ យើង អ៊ិន-តាំ ប្រធានរដ្ឋសភា ក្នុងនាមប្រជាជាតិខ្មែរ សូមប្រកាសជាឱឡារិកនៅថ្ងៃទី៩ តុលា ១៩៧០ ចាប់តាំងពីម៉ោង៧នេះទៅ ចាត់ទុកប្រទេសកម្ពុជាជាសាធារណរដ្ឋតែមួយ ដែលបែងចែកពុំបាន ហើយដែលមានឈ្មោះជាផ្លូវការថា «សាធារណរដ្ឋខ្មែរ» ។

⌘ ⌘

⌘